គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល
លេខៈ ០៤/១៥ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម
ភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១៥

# សេចក្តីណែនាំ
# ស្តីពី
# ការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ

**យោង** : -លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស
-ច្បាប់ស្តីអំពីគណបក្សនយោបាយជំពូកទី ៣ មាត្រា ១៥
-សំណូមពរការងារនាដំណាក់កាលបច្ចុប្បន្ន
-សំណើរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល
-មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល** ណែនាំអំពីការគ្រប់គ្រងសមាជិកគណបក្ស ជាកងយោធពលខេមរភូមិន្ទ ដូចខាងក្រោម ៖

## I.**ការបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ៖**

អនុវត្តតាមគោលការណ៍កំណត់នៃច្បាប់ស្តីអំពីគណបក្សនយោបាយ ជំពូកទី ៣ មាត្រា ១៥ ដែលបានចែងថា : "បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ ។ គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំង ក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិទេ ។" គណបក្សមានគោលការណ៍ណែនាំជាបន្តបន្ទាប់រួចហើយ អំពីការរំសាយអង្គការចាត់តាំងគណបក្ស នៅក្នុងស្ថាប័នដែលច្បាប់ហាមឃាត់ និងផ្ទេរជីវភាពសមាជិកគណបក្ស ឲ្យទៅចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្សនៅតាមមូលដ្ឋាននានា ស្របតាមលក្ខន្តិកៈគណបក្ស ។

ដើម្បីបម្រើសំណូមពរ នៃការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ នាដំណាក់កាលបច្ចុប្បន្ន ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ចំណុះគណៈកម្មាធិការនៃគណបក្ស ៣ថ្នាក់ រួមមាន :

១.គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ថ្នាក់កណ្តាល ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា "គណៈកម្មការ ក.២៦" ។

២.គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ថ្នាក់រាជធានី ខេត្ត ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា "គណៈកម្មការ ខ.២៦" ។

៣.គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា "គណៈកម្មការ ស.២៦" ។

II.**តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ថ្នាក់កណ្តាល (គណៈកម្មការ ក.២៦)**:

**១.តួនាទី** :

គណៈកម្មការ ក.២៦ មានតួនាទីជំនួយការជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ក្នុងការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ។

**២.ភារកិច្ច** :

គណៈកម្មការ ក.២៦ មានភារកិច្ចដូចខាងក្រោម ៖

- ផ្អែកលើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ សេចក្តីកំណត់នានារបស់គណបក្ស និងច្បាប់បញ្ញត្តិជាធរមាន ដើម្បីផ្សព្វផ្សាយ ណែនាំដល់សមាជិកគណបក្ស ក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ចូលរួមអនុវត្តស្របតាមសភាពការណ៍ និងភារកិច្ចជាក់ស្តែងនៃដំណាក់កាលនីមួយៗ ។
- ចាត់តាំងអនុវត្តរបបប្រជុំជីវភាពសមាជិកគណបក្ស ថែបំប៉ន អប់រំ ពង្រឹងសមាជិកគណបក្សខាងនយោបាយ សតិអារម្មណ៍ លើកកម្ពស់គុណធម៌ សីលធម៌ស្អាតស្អំ ថែរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងចូលរួមអនុវត្តកម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ។
- លើកឡើងនូវគោលការណ៍ វិធានការ ដើម្បីពង្រឹងការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ សំដៅធានាបានទាំងបរិមាណ និងគុណភាព ។
- រួមសហការជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីពង្រឹងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ នៅគ្រប់ថ្នាក់ ។
- ណែនាំភារកិច្ចជាក់ស្តែង និងកំណត់អំពីទំនាក់ទំនងរវាងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ បណ្តាថ្នាក់ ស្របតាមរចនាសម្ព័ន្ធនៃការគ្រប់គ្រងសមាជិកគណបក្ស ។

- លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល សម្រេចអំពីការរៀបចំក្រុមសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ឲ្យចូលរួមជីវភាពបក្សចំណុះអង្គការចាត់តាំងគណបក្សណាមួយ ស្របតាមលក្ខន្តិកៈគណបក្ស ។

៣.<u>អង្គការចាត់តាំង</u> :

-គណៈកម្មការ ក.២៦ ត្រូវបានរៀបចំឲ្យមានចំនួនសមស្រប ដើម្បីគ្រប់គ្រងសមាជិកគណបក្ស ។ គណៈអចិន្ត្រៃយ៍គណៈកម្មការ ក.២៦ ដែលរួមមានប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ មានចំនួនមិនលើស ១/៣ នៃចំនួនសមាជិកគណៈកម្មការទាំងមូល ។

- សមាសភាពនៃគណៈកម្មការ ក.២៦ រួមមានមន្ត្រីគណបក្ស ដែលមានលក្ខណសម្បត្តិល្អប្រពៃនៃក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ បញ្ជាការដ្ឋានកងកម្លាំងជំនាញនានា ទីចាត់ការ និងការិយាល័យសំខាន់ៗ យោធភូមិភាគ កងពលមួយចំនួន និងមានមន្ត្រីគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ១រូប ជាសមាជិក ។

- គណៈកម្មការ ក.២៦ មានក្រុមជំនួយការ ដើម្បីជួយការងាររៀបចំទម្រង់បែបបទ លិខិតស្នាមបញ្ជីគ្រប់គ្រងសមាជិកគណបក្ស ។

- គណៈកម្មការ ក.២៦ អាចសម្រេចរៀបចំអនុគណៈកម្មការតាមការចាំបាច់ ដែលត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "អនុគណៈកម្មការ ក.២៦១ អនុគណៈកម្មការ ក.២៦២..." ។

- ក្រុមសមាជិកគណបក្សដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការ ក.២៦ ត្រូវរៀបចំឲ្យចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្សចំណុះគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ។

- សំណើរៀបចំគណៈកម្មការ ក.២៦ និងប្រធានក្រុមជំនួយការ ត្រូវដាក់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលពិនិត្យសម្រេច ។

៤.<u>របៀបរបបធ្វើការ</u> :

- គណៈកម្មការ ក.២៦ ធ្វើការតាមរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ភាគតិចគោរពភាគច្រើន ។ ប្រធានទទួលខុសត្រូវរួម និងបែងចែកភារកិច្ច ចាត់តាំងសមាជិកឲ្យទទួលបន្ទុកតាមផ្នែកការងារ និងការគ្រប់គ្រងតាមក្រុមសមាជិកគណបក្ស ។

- គណៈកម្មការ ក.២៦ ប្រជុំមួយឆ្នាំពីរដង ក្នុងករណីចាំបាច់ត្រូវប្រជុំវិសាមញ្ញ និងត្រូវធ្វើរបាយការណ៍ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។ គណៈអចិន្ត្រៃយ៍គណៈកម្មការ ក.២៦ មានភារកិច្ចដោះស្រាយសម្រេចការងារជាប្រចាំ ដើម្បីធានាដំណើរការឲ្យបានទាន់ពេលវេលា ។

- រៀងរាល់ឆ្នាំត្រូវប្រជុំបូកសរុបដកពិសោធន៍ការងារ និងកំណត់ទិសដៅភារកិច្ចបន្ត ។

- គណៈកម្មការ ក.២៦ មានត្រាសម្រាប់ប្រើប្រាស់ក្នុងការងារគ្រប់គ្រងសមាជិកគណបក្ស ។

- ការរៀបចំបង្កើតក្រុមសមាជិកគណបក្ស ការផ្ទេរជីវភាពបក្ស ការបញ្ចូលសមាជិកគណបក្ស ការសរសើរ និងដាក់វិន័យសមាជិកគណបក្ស ត្រូវចេញសេចក្តីសម្រេចដោយគណៈកម្មាធិការគណបក្ស ដែលទទួលបន្ទុកដឹកនាំគ្រប់គ្រងក្រុមសមាជិកគណបក្សនោះ ស្របតាមលក្ខន្តិកៈគណបក្ស ។

- ការប្រជុំសមាជិកគណបក្សត្រូវធ្វើនៅទីស្នាក់ការគណបក្ស ឬនៅផ្ទះមន្ត្រី សមាជិកគណបក្ស និងស្ថិតនៅក្រៅម៉ោងការងាររដ្ឋ មិនត្រូវប្រជុំនៅកន្លែងនិងអាគាររបស់រដ្ឋ ហើយសមាជិកដែលមកចូលរួមមិនត្រូវប្រើប្រាស់មធ្យោបាយរបស់រដ្ឋ មិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់ខ្លួនឡើយ ។

## III.<u>តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ</u>

១.<u>តួនាទី</u> :

គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីជំនួយការជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ នៅយោធភូមិភាគ តំបន់ប្រតិបត្តិការសឹករង ផ្នែកសឹករង អង្គភាព វិទ្យាស្ថាន និងសាលាយោធា ដែលមានមូលដ្ឋានឈរជើងក្នុងភូមិសាស្ត្រនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ របស់ខ្លួន ។

២.<u>ភារកិច្ច</u> :

គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចខាងក្រោម ៖

- ចាត់តាំងអនុវត្តរបបប្រជុំជីវភាពសមាជិកគណបក្ស ថែបំប៉ន អប់រំពង្រឹងសមាជិកគណបក្សខាងនយោបាយ សតិអារម្មណ៍ លើកកម្ពស់គុណធម៌ សីលធម៌ស្អាតស្អំ ថែរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងចូលរួមអនុវត្តកម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ។

- ចាត់តាំងអនុវត្តគោលការណ៍ណែនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរបស់គណៈកម្មការ ក.២៦ ។

- លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រេចអំពីការរៀបចំក្រុមសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ឲ្យចូលរួមជីវភាពបក្សចំណុះអង្គការចាត់តាំងគណបក្សណាមួយ ស្របតាមលក្ខន្តិកៈគណបក្ស ។

៣.<u>អង្គការចាត់តាំង</u> :

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ឲ្យមានចំនួន ៧រូបចុះ ។

- សមាសភាពនៃគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស រួមមានមន្ត្រីគណបក្សដែលមានលក្ខណសម្បត្តិល្អប្រពៃ ជាមេបញ្ជាការ មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករង ផ្នែកសឹករង កងរាជអាវុធហត្ថរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាយទាហានដែលមានតួនាទីសំខាន់ៗ និងមានមន្ត្រីគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ១រូប ជាសមាជិក ។

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស មានក្រុមជំនួយការ ដើម្បីជួយការងាររៀបចំទម្រង់បែបបទ លិខិតស្នាម បញ្ជីគ្រប់គ្រងសមាជិកគណបក្ស ។

- សំណើរៀបចំគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស និងប្រធានក្រុមជំនួយការថ្នាក់ណាត្រូវដាក់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ថ្នាក់នោះពិនិត្យសម្រេច ។

- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវណែនាំដាក់ស្តែងអំពីការរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួននៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ស្របតាមស្មារតីនៃសេចក្តីណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។ ទន្ទឹមនេះ ត្រូវរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ដែលមានភារកិច្ចឈរជើងក្នុងភូមិសាស្ត្ររបស់ខ្លួនតាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល (តាមសំណើរបស់គណៈ កម្មការ ក.២៦) ។

៤.<u>របៀបរបបធ្វើការ</u> :

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ធ្វើការតាមរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ភាគតិចគោរពភាគច្រើន ។

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ប្រជុំមួយខែម្តង ក្នុងករណីចាំបាច់ត្រូវប្រជុំវិសាមញ្ញ និងត្រូវធ្វើរបាយការណ៍ជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងធ្វើរបាយការណ៍តាមគោលការណ៍កំណត់របស់គណៈកម្មការ ក.២៦ ។

- ការរៀបចំបង្កើតក្រុមសមាជិកគណបក្ស ការបញ្ចូលសមាជិកគណបក្ស ការផ្ទេរជីវភាពបក្ស ការសរសើរ និងដាក់វិន័យសមាជិកគណបក្ស ត្រូវចេញសេចក្តីសម្រេចដោយគណៈកម្មាធិការគណបក្សដែលទទួលបន្ទុកដឹកនាំគ្រប់គ្រងក្រុមសមាជិកគណបក្សនោះ ស្របតាមលក្ខន្តិកៈគណបក្ស។

-ការប្រជុំសមាជិកគណបក្សត្រូវធ្វើនៅទីស្នាក់ការគណបក្ស ឬនៅផ្ទះមន្ត្រី សមាជិកគណបក្ស និងស្ថិតនៅក្រៅម៉ោងការងាររដ្ឋ មិនត្រូវប្រជុំនៅកន្លែងនិងអាគាររបស់រដ្ឋ ហើយសមាជិកដែលមកចូលរួមមិនត្រូវប្រើប្រាស់មធ្យោបាយរបស់រដ្ឋ មិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់ខ្លួនឡើយ។

៨.<u>ការប្រើឈ្មោះគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាអក្សរកាត់</u> :

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់រាជធានី ខេត្ត ត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "គណៈកម្មការ ខ.២៦" និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "គណៈកម្មការ ស.២៦" ។

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ ដែលមានភារកិច្ចឈរជើងក្នុងភូមិសាស្ត្រ ហើយត្រូវបានបង្កើតឡើងតាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលឲ្យស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សថ្នាក់ រាជធានី ខេត្ត ត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "គណៈកម្មការ ខ.២៦១ គណៈកម្មការ ខ.២៦២...." និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "គណៈកម្មការ ស.២៦១ គណៈកម្មការ ស.២៦២..." ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះ ។

ជ.គណៈអចិន្ត្រៃយ៍
ប្រធាន

ជា ស៊ីម

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ:០៣/១៥ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១៥

# សេចក្តីណែនាំ
# ស្តីពី
# ការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ

**យោង** : -លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស
-ច្បាប់ស្តីអំពីគណបក្សនយោបាយជំពូកទី ៣ មាត្រា ១៥
-សំណូមពរការងារនាដំណាក់កាលបច្ចុប្បន្ន
-សំណើរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល
-មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល** ណែនាំអំពីការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ដូចខាងក្រោម ៖

## I.ការបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ៖

អនុវត្តតាមគោលការណ៍កំណត់នៃច្បាប់ស្តីអំពីគណបក្សនយោបាយ ជំពូកទី ៣ មាត្រា ១៥ ដែលបានចែងថា : "បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ ។ គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិទេ ។" គណបក្សមានគោលការណ៍ណែនាំជាបន្តបន្ទាប់រួចហើយ អំពីការរំសាយអង្គការចាត់តាំងគណបក្សនៅក្នុងស្ថាប័នដែលច្បាប់ហាមឃាត់ និងផ្ទេរជីវភាពសមាជិកគណបក្ស ឲ្យទៅចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្ស នៅតាមមូលដ្ឋាននានា ស្របតាមលក្ខន្តិកៈគណបក្ស ។

ដើម្បីបម្រើសំណូមពរ នៃការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ នាដំណាក់កាលបច្ចុប្បន្ន ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ចំណុះគណៈកម្មាធិការនៃគណបក្ស ៣ថ្នាក់ រួមមាន ៖

១.គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ថ្នាក់កណ្តាល ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា "គណៈកម្មការ ក.២៧" ។

២.គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា "គណៈកម្មការ ខ.២៧" ។

៣.គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកម្លាំងនគរបាលជាតិ ថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា " គណៈកម្មការ ស.២៧" ។

## II.តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ថ្នាក់កណ្តាល (គណៈកម្មការ ក.២៧)

**១.តួនាទី ៖**

គណៈកម្មការ ក.២៧ មានតួនាទីជំនួយការជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ក្នុងការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ។

**២.ភារកិច្ច ៖**

គណៈកម្មការ ក.២៧ មានភារកិច្ចដូចខាងក្រោម ៖

-ផ្អែកលើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ សេចក្តីកំណត់នានារបស់គណបក្ស និងច្បាប់បញ្ញត្តិជាធរមាន ដើម្បីផ្សព្វផ្សាយ ណែនាំដល់សមាជិកគណបក្ស ក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ចូលរួមអនុវត្តស្របតាមសភាពការណ៍ និងភារកិច្ចជាក់ស្តែង នៃដំណាក់កាលនីមួយៗ ។

-ចាត់តាំងអនុវត្តរបបប្រជុំជីវភាពសមាជិកគណបក្ស ថែបំប៉ន អប់រំ ពង្រឹងសមាជិកគណបក្សខាងនយោបាយ សតិអារម្មណ៍ លើកកម្ពស់គុណធម៌ សីលធម៌ស្អាតស្អំ ថែរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងចូលរួមអនុវត្តកម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ។

-លើកឡើងនូវគោលការណ៍ វិធានការ ដើម្បីពង្រឹងការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ សំដៅធានាបានទាំងបរិមាណ និងគុណភាព ។

-រួមសហការជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីពង្រឹងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ នៅគ្រប់ថ្នាក់ ។

-ណែនាំភារកិច្ចជាក់ស្តែង និងកំណត់អំពីទំនាក់ទំនងរវាងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ បណ្តាថ្នាក់ ស្របតាមរចនាសម្ព័ន្ធនៃការគ្រប់គ្រងសមាជិកគណបក្ស ។

-លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល សម្រេចអំពីការរៀបចំក្រុមសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ឲ្យចូលរួមជីវភាពបក្សចំណុះអង្គការចាត់តាំងគណបក្សណាមួយ ស្របតាមលក្ខន្តិកៈគណបក្ស ។

៣.<u>អង្គការចាត់តាំង</u> **:**

-គណៈកម្មការ ក.២៧ ត្រូវបានរៀបចំឲ្យមានចំនួនសមស្រប ដើម្បីគ្រប់គ្រងសមាជិកគណបក្ស ។ គណៈអចិន្ត្រៃយ៍គណៈកម្មការ ក.២៧ ដែលរួមមានប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ មានចំនួនមិនលើស ១/៣ នៃចំនួនសមាជិកគណៈកម្មការទាំងមូល ។

-សមាសភាពនៃគណៈកម្មការ ក.២៧ រួមមានមន្ត្រីគណបក្ស ដែលមានលក្ខណសម្បត្តិល្អប្រពៃនៃក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋានកណ្តាល នាយកដ្ឋាន និងផ្នែកសំខាន់ៗ បណ្ឌិតសភានគរបាល និងមានមន្ត្រីគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ១រូប ជាសមាជិក ។

-គណៈកម្មការ ក.២៧ មានក្រុមជំនួយការ ដើម្បីជួយការងាររៀបចំទម្រង់បែបបទ លិខិតស្នាម បញ្ជីគ្រប់គ្រងសមាជិកគណបក្ស ។

-គណៈកម្មការ ក.២៧ អាចសម្រេចរៀបចំអនុគណៈកម្មការតាមការចាំបាច់ ដែលត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "អនុគណៈកម្មការ ក.២៧១ អនុគណៈកម្មការ ក.២៧២..." ។

-ក្រុមសមាជិកគណបក្សដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការ ក.២៧ ត្រូវរៀបចំឲ្យចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្សចំណុះគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ។

-សំណើរៀបចំគណៈកម្មការ ក.២៧ និងប្រធានក្រុមជំនួយការ ត្រូវដាក់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលពិនិត្យសម្រេច ។

៤.<u>របៀបរបបធ្វើការ</u> **:**

-គណៈកម្មការ ក.២៧ ធ្វើការតាមរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ភាគតិចគោរពភាគច្រើន។ ប្រធានទទួលខុសត្រូវរួម និងបែងចែកភារកិច្ច ចាត់តាំងសមាជិកឲ្យទទួលបន្ទុកតាមផ្នែកការងារ និងការគ្រប់គ្រងតាមក្រុមសមាជិកគណបក្ស ។

-គណៈកម្មការ ក.២៧ ប្រជុំមួយឆ្នាំពីរដង ក្នុងករណីចាំបាច់ត្រូវប្រជុំវិសាមញ្ញ និងត្រូវធ្វើរបាយការណ៍ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។ គណៈអចិន្ត្រៃយ៍គណៈកម្មការ ក.២៧ មានភារកិច្ចដោះស្រាយសម្រេចការងារជាប្រចាំ ដើម្បីជានាដំណើរការឲ្យបានទាន់ពេលវេលា ។

-រៀងរាល់ឆ្នាំត្រូវប្រជុំបូកសរុបដកពិសោធន៍ការងារ និងកំណត់ទិសដៅភារកិច្ចបន្ត ។

-គណៈកម្មការ ក.២៧ មានត្រាសម្រាប់ប្រើប្រាស់ក្នុងការងារគ្រប់គ្រងសមាជិកគណបក្ស ។

-ការរៀបចំបង្កើតក្រុមសមាជិកគណបក្ស ការផ្ទេរជីវភាពបក្ស ការបញ្ចូលសមាជិកគណបក្ស ការសរសើរ និងដាក់វិន័យសមាជិកគណបក្ស ត្រូវចេញសេចក្តីសម្រេចដោយគណៈកម្មាធិការគណបក្ស ដែលទទួលបន្ទុកដឹកនាំគ្រប់គ្រងក្រុមសមាជិកគណបក្សនោះ ស្របតាមលក្ខន្តិកៈគណបក្ស ។

-ការប្រជុំសមាជិកគណបក្សត្រូវធ្វើនៅទីស្នាក់ការគណបក្ស ឬនៅផ្ទះមន្ត្រី សមាជិកគណបក្ស និងស្ថិតនៅក្រៅម៉ោងការងាររដ្ឋ មិនត្រូវប្រជុំនៅកន្លែងនិងអាគាររបស់រដ្ឋ ហើយសមាជិកដែលមកចូលរួមមិនត្រូវប្រើប្រាស់មធ្យោបាយរបស់រដ្ឋ មិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់ខ្លួនឡើយ។

## III.<u>តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ</u>

### ១.<u>តួនាទី</u> ៖

គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីជំនួយការជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ នៅស្នងការដ្ឋាននគរបាល អធិការដ្ឋាននគរបាល អង្គភាព និងសាលានគរបាល ដែលមានមូលដ្ឋានឈរជើងក្នុងភូមិសាស្ត្រនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ របស់ខ្លួន ។

### ២.<u>ភារកិច្ច</u> ៖

គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចខាងក្រោម ៖

-ចាត់តាំងអនុវត្តរបបប្រជុំជីវភាពសមាជិកគណបក្ស ថែបំប៉ន អប់រំពង្រឹងសមាជិកគណបក្សខាងនយោបាយ សតិអារម្មណ៍ លើកកម្ពស់គុណធម៌ សីលធម៌ស្អាតស្អំ ថែរក្សាសាមគ្គីភាពឯកភាពផ្ទៃក្នុង និងចូលរួមអនុវត្តកម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ។

-ចាត់តាំងអនុវត្តគោលការណ៍ណែនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងរបស់គណៈកម្មការ ក.២៧ ។

-លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រេចអំពីការរៀបចំក្រុមសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ឲ្យចូលរួមជីវភាពបក្សចំណុះអង្គការចាត់តាំងគណបក្សណាមួយ ស្របតាមលក្ខន្តិកៈគណបក្ស ។

### ៣.<u>អង្គការចាត់តាំង</u> ៖

-គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ឲ្យមានចំនួន ៧រូបចុះ ។

-សមាសភាពនៃគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស រួមមានមន្ត្រីគណបក្សដែលមានលក្ខណសម្បត្តិល្អប្រពៃ ជាស្នងការ ស្នងការរង អធិការ អធិការរង នាយនគរបាល ដែលមានតួនាទីសំខាន់ៗ និងមានមន្ត្រីគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ១រូប ជាសមាជិក ។

-គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស មានក្រុមជំនួយការ ដើម្បីជួយការងាររៀបចំទម្រង់បែបបទ លិខិតស្នាម បញ្ជីគ្រប់គ្រងសមាជិកគណបក្ស ។

-សំណើរៀបចំគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស និងប្រធានក្រុមជំនួយការថ្នាក់ណា ត្រូវដាក់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ថ្នាក់នោះ ពិនិត្យសម្រេច ។

-គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវណែនាំដាក់ស្តែងអំពីការរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួននៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ស្របតាមស្មារតីនៃសេចក្តីណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។ ទន្ទឹមនេះ ត្រូវរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ដែលមានភារកិច្ចឈរជើងក្នុងភូមិសាស្ត្ររបស់ខ្លួនតាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល (តាមសំណើរបស់គណៈកម្មការ ក.២៧)។ ដោយឡែក ចំពោះសមាជិកគណបក្សជានគរបាលនៃប៉ុស្តិ៍រដ្ឋបាលត្រូវរៀបចំឲ្យចូលរួមប្រជុំជីវភាពបក្ស នៅក្នុងសាខាគណបក្សនៃសាលាឃុំ សង្កាត់ ។

៨.<u>របៀបរបបធ្វើការ</u> ៈ

-គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ធ្វើការតាមរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ភាគតិចគោរពភាគច្រើន ។

-គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ប្រជុំមួយខែម្តង ក្នុងករណីចាំបាច់ត្រូវប្រជុំវិសាមញ្ញ និងត្រូវធ្វើរបាយការណ៍ជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងធ្វើរបាយការណ៍តាមគោលការណ៍កំណត់របស់គណៈកម្មការ ក.២៧ ។

-ការរៀបចំបង្កើតក្រុមសមាជិកគណបក្ស ការបញ្ចូលសមាជិកគណបក្ស ការផ្ទេរជីវភាពបក្ស ការសរសើរ និងដាក់វិន័យសមាជិកគណបក្ស ត្រូវចេញសេចក្តីសម្រេចដោយគណៈកម្មាធិការគណបក្សដែលទទួលបន្ទុកដឹកនាំគ្រប់គ្រងក្រុមសមាជិកគណបក្សនោះ ស្របតាមលក្ខន្តិកៈគណបក្ស។

-ការប្រជុំសមាជិកគណបក្សត្រូវធ្វើនៅទីស្នាក់ការគណបក្ស ឬនៅផ្ទះមន្ត្រី សមាជិកគណបក្ស និងស្ថិតនៅក្រៅម៉ោងការងាររដ្ឋ មិនត្រូវប្រជុំនៅកន្លែងនិងអាគាររបស់រដ្ឋ ហើយសមាជិកដែលមកចូលរួមមិនត្រូវប្រើប្រាស់មធ្យោបាយរបស់រដ្ឋ មិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់ខ្លួនឡើយ។

៩.<u>ការប្រើឈ្មោះគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាអក្សរកាត់</u> :

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់រាជធានី ខេត្ត ត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា"គណៈកម្មការខ.២៧" និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "គណៈកម្មការ ស.២៧" ។

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ដែលមានភារកិច្ចឈរជើងក្នុងភូមិសាស្ត្រ ហើយត្រូវបានបង្កើតឡើងតាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលឲ្យស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សថ្នាក់រាជធានី ខេត្ត ត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "គណៈកម្មការ ខ.២៧១ គណៈកម្មការ ខ.២៧២...." និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានប្រើឈ្មោះជាអក្សរកាត់ថា "គណៈកម្មការ ស.២៧១ គណៈកម្មការ ស.២៧២..." ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះ ។

ជ. គណៈអចិន្ត្រៃយ៍

ប្រធាន

ជា ស៊ីម

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល
លេខ:០៥/១៥ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម
ភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១៥

# សេចក្តីណែនាំ
# ស្តីពី
# ការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ

**<u>យោង</u> :** -លក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងគណបក្ស
-ច្បាប់ស្តីអំពីគណបក្សនយោបាយជំពូកទី ៣ មាត្រា ១៥
-សំណូមពរការងារនាដំណាក់កាលបច្ចុប្បន្ន
-សំណើរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល
-មតិឯកភាពរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល** ណែនាំអំពីការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ ដូចខាងក្រោម ៖

## I.<u>ការបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ</u> ៖

អនុវត្តតាមគោលការណ៍កំណត់នៃច្បាប់ស្តីអំពីគណបក្សនយោបាយ ជំពូកទី ៣ មាត្រា ១៥ ដែលបានចែងថា : "បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ ។ គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំង ក្នុងស្ថាប័នសាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិទេ ។" គណបក្សមានគោលការណ៍ណែនាំជាបន្តបន្ទាប់រួចហើយ អំពីការរំសាយអង្គការចាត់តាំងគណបក្សនៅក្នុងស្ថាប័នដែលច្បាប់ហាមឃាត់ និងផ្ទេរជីវភាពសមាជិកគណបក្ស ឲ្យទៅចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្ស នៅតាមមូលដ្ឋាននានា ស្របតាមលក្ខន្តិកៈគណបក្ស ។

ដើម្បីបម្រើសំណូមពរ នៃការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ នាដំណាក់កាលបច្ចុប្បន្ន ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ចំណុះគណៈកម្មាធិការនៃគណបក្ស ២ថ្នាក់ រួមមាន ៖

១.គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៃសាលាជម្រះក្ដីជាន់ខ្ពស់ និងមហាអយ្យការអមសាលាជម្រះក្ដីជាន់ខ្ពស់ ចំណុះថ្នាក់កណ្ដាល ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា "គណៈកម្មការ ក.១៨" ។

២.គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៃសាលាដំបូង និងអយ្យការអមសាលាដំបូង ចំណុះថ្នាក់រាជធានី ខេត្ត ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា "គណៈកម្មការ ខ.១៨" ។

II.**<u>តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៃសាលាជម្រះក្ដីជាន់ខ្ពស់ និងមហាអយ្យការអមសាលាជម្រះក្ដីជាន់ខ្ពស់ ចំណុះថ្នាក់កណ្ដាល (គណៈកម្មការ ក.១៨)</u>**

**១.<u>តួនាទី</u> ៖**

គណៈកម្មការ ក.១៨ មានតួនាទីជំនួយការជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ក្នុងការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល និងសមាជិកគណបក្សជាមន្ត្រីសាលាឧទ្ធរណ៍ និងអយ្យការអមសាលាឧទ្ធរណ៍ ។

**២.<u>ភារកិច្ច</u> ៖**

គណៈកម្មការ ក.១៨ មានភារកិច្ចដូចខាងក្រោម ៖

-ផ្អែកលើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ សេចក្ដីកំណត់នានារបស់គណបក្ស និងច្បាប់បញ្ញត្តិជាធរមាន ដើម្បីផ្សព្វផ្សាយ ណែនាំដល់សមាជិកគណបក្ស ក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ចូលរួមអនុវត្តស្របតាមសភាពការណ៍ និងភារកិច្ចជាក់ស្ដែង នៃដំណាក់កាលនីមួយៗ ។

-ចាត់តាំងអនុវត្តរបបប្រជុំជីវភាពសមាជិកគណបក្ស ថែបំប៉ន អប់រំពង្រឹងសមាជិកគណបក្សខាងនយោបាយ សតិអារម្មណ៍ លើកកម្ពស់គុណធម៌ សីលធម៌ស្អាតស្អំ ថែរក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងចូលរួមអនុវត្តកម្មវិធីនយោបាយ សេចក្ដីសម្រេចនានារបស់គណបក្ស ។

-លើកឡើងនូវគោលការណ៍ វិធានការ ដើម្បីពង្រឹងការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ សំដៅជានាបានទាំងបរិមាណ និងគុណភាព ។

-រួមសហការជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ដើម្បីពង្រឹងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ ថ្នាក់រាជធានី ខេត្ត ។

-លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល សម្រេចអំពីការរៀបចំក្រុមសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ ឲ្យចូលរួមជីវភាពបក្សចំណុះអង្គការចាត់តាំងគណបក្សណាមួយ ស្របតាមលក្ខន្តិកៈគណបក្ស ។

៣.<u>អង្គការចាត់តាំង</u> ៖

-គណៈកម្មការ ក.១៨ ត្រូវបានកំណត់ឲ្យមានចំនួន ២១រូប ចុះ។ គណៈអចិន្ត្រៃយ៍គណៈកម្មការ ក.១៨ ដែលរួមមានប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ មានចំនួនមិនលើស ១/៣ នៃចំនួនសមាជិកគណៈកម្មការទាំងមូល ។

-សមាសភាពនៃគណៈកម្មការ ក.១៨ រួមមានមន្ត្រីគណបក្ស ដែលមានលក្ខណសម្បត្តិល្អប្រពៃនៃតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល សាលាឧទ្ធរណ៍ និងអយ្យការអមសាលាឧទ្ធរណ៍ និងមានមន្ត្រីគណៈកម្មាធិការគណបក្សក្រសួងយុត្តិធម៌ ១រូប ជាសមាជិក មន្ត្រីគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ១រូប ជាសមាជិក ។

-គណៈកម្មការ ក.១៨ មានក្រុមជំនួយការ ដើម្បីជួយការងាររៀបចំទម្រង់បែបបទ លិខិតស្នាមបញ្ជីគ្រប់គ្រងសមាជិកគណបក្ស ។

-ក្រុមសមាជិកគណបក្សដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការ ក.១៨ ត្រូវរៀបចំឲ្យចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្សចំណុះគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ។

-សំណើរៀបចំគណៈកម្មការ ក.១៨ និងប្រធានក្រុមជំនួយការ ត្រូវដាក់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ពិនិត្យសម្រេច ។

៤.<u>របៀបរបបធ្វើការ</u> ៖

-គណៈកម្មការ ក.១៨ ធ្វើការតាមរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ភាគតិចគោរពភាគច្រើន។ ប្រធានទទួលខុសត្រូវរួម និងបែងចែកភារកិច្ច ចាត់តាំងសមាជិកឲ្យទទួលបន្ទុកតាមផ្នែកការងារ និងការគ្រប់គ្រងតាមក្រុមសមាជិកគណបក្ស ។

-គណៈកម្មការ ក.១៨ ប្រជុំមួយខែម្តង ក្នុងករណីចាំបាច់ត្រូវប្រជុំវិសាមញ្ញ និងត្រូវធ្វើរបាយការណ៍ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។ គណៈអចិន្ត្រៃយ៍គណៈកម្មការ ក.១៨ មានភារកិច្ចដោះស្រាយសម្រេចការងារជាប្រចាំ ដើម្បីជានាដំណើរការឲ្យបានទាន់ពេលវេលា ។

-រៀងរាល់ឆ្នាំត្រូវប្រជុំបូកសរុបដកពិសោធន៍ការងារ និងកំណត់ទិសដៅភារកិច្ចបន្ត ។

-គណៈកម្មការ ក.១៨ មានត្រាសម្រាប់ប្រើប្រាស់ក្នុងការងារគ្រប់គ្រងសមាជិកគណបក្ស ។

-ការរៀបចំបង្កើតក្រុមសមាជិកគណបក្ស ការផ្ទេរជីវភាពបក្ស ការបញ្ចូលសមាជិកគណបក្ស ការសរសើរ និងដាក់វិន័យសមាជិកគណបក្ស ត្រូវចេញសេចក្តីសម្រេចដោយគណៈកម្មាធិការគណបក្ស ដែលទទួលបន្ទុកដឹកនាំគ្រប់គ្រងក្រុមសមាជិកគណបក្សនោះ ស្របតាមលក្ខន្តិកៈគណបក្ស ។

-ការប្រជុំសមាជិកគណបក្សត្រូវធ្វើនៅទីស្នាក់ការគណបក្ស ឬនៅផ្ទះមន្ត្រី សមាជិកគណបក្ស និងស្ថិតនៅក្រៅម៉ោងការងាររដ្ឋ មិនត្រូវប្រជុំនៅកន្លែងនិងអាគាររបស់រដ្ឋ ហើយសមាជិកដែលមកចូលរួមមិនត្រូវប្រើប្រាស់មធ្យោបាយរបស់រដ្ឋ និងមិនត្រូវស្លៀកពាក់ឯកសណ្ឋានឡើយ ។

III.**<u>តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីសាលាដំបូង និងអយ្យការអមសាលាដំបូងចំណុះថ្នាក់រាជធានី ខេត្ត (គណៈកម្មការ ខ.១៨)</u>**

**១.<u>តួនាទី</u> :**

គណៈកម្មការ ខ.១៨ ចំណុះថ្នាក់រាជធានី ខេត្ត មានតួនាទីជំនួយការជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្នុងការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ។

**២.<u>ភារកិច្ច</u> :**

គណៈកម្មការ ខ.១៨ ចំណុះថ្នាក់រាជធានី ខេត្ត មានភារកិច្ចដូចខាងក្រោម :

-ចាត់តាំងអនុវត្តរបបប្រជុំជីវភាពសមាជិកគណបក្ស ថែបំប៉ន អប់រំពង្រឹងសមាជិកគណបក្សខាងនយោបាយ សតិអារម្មណ៍ លើកកម្ពស់គុណធម៌ សីលធម៌ស្អាតស្អំ ថែរក្សាសាមគ្គីភាពឯកភាពផ្ទៃក្នុង និងចូលរួមអនុវត្តកម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ។

-ចាត់តាំងអនុវត្តគោលការណ៍ណែនាំរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងរបស់គណៈកម្មការ ក.១៨ ។

-លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត សម្រេចអំពីការរៀបចំក្រុមសមាជិកគណបក្សជាមន្ត្រីសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ឲ្យចូលរួមជីវភាពបក្សចំណុះអង្គការចាត់តាំងគណបក្សណាមួយ ស្របតាមលក្ខន្តិកៈគណបក្ស ។

**៣.<u>អង្គការចាត់តាំង</u> :**

-គណៈកម្មការ ខ.១៨ ចំណុះថ្នាក់រាជធានី ខេត្ត ត្រូវបានកំណត់ឲ្យមានចំនួន ៧រូបចុះ ។

-សមាសភាពនៃគណៈកម្មការ ខ.១៨ រួមមានមន្ត្រីគណបក្ស ដែលមានលក្ខណសម្បត្តិល្អប្រពៃ នៃសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត និងមានមន្ត្រីគណបក្សរាជធានី ខេត្ត ១រូប ជាសមាជិក ។

-គណៈកម្មការ ខ.១៨ មានក្រុមជំនួយការ ដើម្បីជួយការងាររៀបចំទម្រង់បែបបទ លិខិតស្នាមបញ្ជីគ្រប់គ្រងសមាជិកគណបក្ស ។

-សំណើរៀបចំគណៈកម្មការ ខ.១៨ និងប្រធានក្រុមជំនួយការត្រូវដាក់ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ពិនិត្យសម្រេច ។

**៤.របៀបរបបធ្វើការ ៖**

-គណៈកម្មការ ខ.១៨ ធ្វើការតាមរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ភាគតិចគោរពភាគច្រើន ។

-គណៈកម្មការ ខ.១៨ ប្រជុំមួយខែម្តង ក្នុងករណីចាំបាច់ត្រូវប្រជុំវិសាមញ្ញ និងត្រូវធ្វើរបាយការណ៍ជូនគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ។

-ការរៀបចំបង្កើតក្រុមសមាជិកគណបក្ស ការបញ្ចូលសមាជិកគណបក្ស ការផ្ទេរជីវភាពបក្ស ការសរសើរ និងដាក់វិន័យសមាជិកគណបក្ស ត្រូវចេញសេចក្តីសម្រេចដោយគណៈកម្មាធិការគណបក្សដែលទទួលបន្ទុកដឹកនាំគ្រប់គ្រងក្រុមសមាជិកគណបក្សនោះ ស្របតាមលក្ខន្តិកៈគណបក្ស។

-ការប្រជុំសមាជិកគណបក្សត្រូវធ្វើនៅទីស្នាក់ការគណបក្ស ឬនៅផ្ទះមន្ត្រី សមាជិកគណបក្ស និងស្ថិតនៅក្រៅម៉ោងការងាររដ្ឋ មិនត្រូវប្រជុំនៅកន្លែងនិងអាគាររបស់រដ្ឋ ហើយសមាជិកដែលមកចូលរួមមិនត្រូវប្រើប្រាស់មធ្យោបាយរបស់រដ្ឋ និងមិនត្រូវស្លៀកពាក់ឯកសណ្ឋានឡើយ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ គណៈកម្មាធិការគណបក្សក្រសួងយុត្តិធម៌ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះ ។

ជ.គណៈអចិន្ត្រៃយ៍

ប្រធាន

ជា ស៊ីម

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**លេខ**: ០០៥/២០ **សណ.គក**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃពុធ ៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០២០

# សេចក្តីណែនាំ
## ស្តីពី
## ការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់

**យោង** : - សេចក្តីណែនាំលេខ ០៥/១៥ សណ.គក ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៥
- សំណូមពរការងារគណបក្សនាដំណាក់កាលបច្ចុប្បន្ន
- សំណើរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល
- មតិរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំអំពីការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ដូចខាងក្រោម :

១. បង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ដែលត្រូវបានប្រើឈ្មោះសម្គាល់ជាអក្សរកាត់ថា "គណៈកម្មការ ខ.១៨-២" ស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សខេត្តនៃទីតាំងសាលាឧទ្ធរណ៍តំបន់ ។

២. គណៈកម្មការ ខ.១៨-២ មានតួនាទីជំនួយការជូនគណៈកម្មាធិការគណបក្សខេត្ត ក្នុងការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ ។

៣. គណៈកម្មការ ខ.១៨-២ មានភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការដូចមានចែងក្នុងចំណុច III នៃសេចក្តីណែនាំលេខ ០៥/១៥ សណ.គក ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៥ ។

៤. គណៈកម្មការ ក.១៨ មានភារកិច្ចបន្តគ្រប់គ្រងផ្ទាល់សមាជិកគណបក្សជាមន្ត្រីសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ និងមានភារកិច្ចរួមសហការជាមួយគណៈកម្មាធិការគណបក្សខេត្ត ដើម្បីពង្រឹងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ផ្សេងទៀត ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ គណៈកម្មាធិការគណបក្សក្រសួងយុត្តិធម៌ គណៈកម្មការ ក.១៨ និងគណៈកម្មាធិការគណបក្សខេត្តមានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះ ។

**ជ.គណៈអចិន្ត្រៃយ៍**
**ប្រធាន**

**ហ៊ុន សែន**

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៥

# ជំនួយស្មារតី
# សម្រាប់ការអនុវត្តសេចក្តីណែនាំ
# ស្តីពីការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ
# កងកម្លាំងនគរបាលជាតិ និងមន្ត្រីក្នុងអង្គការតុលាការ

អនុវត្តតាមគោលការណ៍កំណត់នៃច្បាប់ស្តីពីគណបក្សនយោបាយជំពូកទី៣ មាត្រា ១៥ គណបក្សមានគោលការណ៍ណែនាំជាបន្តបន្ទាប់រួចហើយ តាំងពីសន្និបាតគណៈកម្មាធិការកណ្តាលលើកទី ២៣ នាខែតុលា ឆ្នាំ ១៩៩៧ អំពីការរំសាយអង្គការចាត់តាំងគណបក្សនៅក្នុងស្ថាប័នដែលច្បាប់ហាមឃាត់ និងផ្ទេរជីវភាពសមាជិកគណបក្សឲ្យទៅចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្សនៅតាមមូលដ្ឋាននានា ស្របតាមលក្ខន្តិកៈគណបក្ស ។

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល បានចេញសេចក្តីណែនាំស្តីពីការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ សេចក្តីណែនាំស្តីពីការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ និងសេចក្តីណែនាំស្តីពីការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៥ ក្នុងគោលបំណងដើម្បីពង្រឹងការគ្រប់គ្រងសមាជិកគណបក្សនៅស្ថាប័ននានាដែលច្បាប់ហាមឃាត់មិនអោយរៀបចំរចនាសម្ព័ន្ធអង្គការចាត់តាំងគណបក្ស ឲ្យមានការឯកភាពគ្នា ស្របតាមគោលការណ៍ច្បាប់កំណត់ និងធានាបាននូវសិទ្ធិនយោបាយរបស់មន្ត្រី សមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងមន្ត្រីនៅក្នុងអង្គការតុលាការ ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូប ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

## I- **អំពីរូបភាពចាត់តាំង**

### 1- **ថ្នាក់កណ្តាល**

- ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៃសាលាជម្រះក្តីជាន់ខ្ពស់ និងមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ ដែលមានតួនាទីជំនួយការជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលក្នុងការគ្រប់គ្រងសមាជិកគណបក្ស ។

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស រួមមានប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកដែលត្រូវបានបែងចែកភារកិច្ចឲ្យទទួលបន្ទុកតាមផ្នែកការងារ និងការគ្រប់គ្រងតាមក្រុមសមាជិកគណបក្ស ។ មន្ត្រីគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលមួយរូបចូលរួមជាសមាជិកគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស (មិនចូលរួមក្នុងគណៈអចិន្ត្រៃយ៍ទេ) ដើម្បីជួយសម្របសម្រួលការងារជំនាញ និងទំនាក់ទំនងជាមួយស្ថាប័នគណបក្សថ្នាក់កណ្តាល ។ ក្នុងចំណោមអនុប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សត្រូវចាត់តាំងអនុប្រធានប្រចាំការមួយរូប ដើម្បីដឹកនាំក្រុមជំនួយការដោះស្រាយការងារប្រចាំថ្ងៃ ។

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ អាចសម្រេចរៀបចំបង្កើតអនុគណៈកម្មការនៅតាមផ្នែក និងអង្គភាពចំណុះតាមការចាំបាច់ ។ អនុគណៈកម្មការនេះអាចរៀបចំបង្កើតដើម្បីគ្រប់គ្រងសមាជិកគណបក្សនៃបញ្ជាការដ្ឋានកម្លាំងទ័ពជំនាញ អគ្គនាយកដ្ឋាន ផ្នែក និងអង្គភាពចំណុះដែលមានមូលដ្ឋានឈរជើងក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ។

2- **<u>ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ</u>**

- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួននៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ និងបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៃសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ។

- ទន្ទឹមនេះ ត្រូវរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ ដែលមានភារកិច្ចឈរជើងក្នុងភូមិសាស្ត្ររបស់ខ្លួន តាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។ ត្រូវរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សនៃយោធភូមិភាគចំណុះថ្នាក់ខេត្ត និងគណៈកម្មការគ្រប់គ្រងសមាជិគណបក្សនៃទីបញ្ជាការសមរភូមិមុខ កងពល អង្គភាពនគរបាលដែលមានភារកិច្ចឈរជើងក្នុងភូមិសាស្ត្រចំណុះថ្នាក់ខេត្ត ឬថ្នាក់ស្រុក ក្រុងដែលនៅជិតមូលដ្ឋានឈរជើងដើម្បីងាយស្រួលក្នុងការដឹកនាំ និងការបំពេញបែបបទសម្រាប់ការគ្រប់គ្រងសមាជិកគណបក្ស ។

- មន្ត្រីគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយរូប ចូលរួមជាសមាជិកគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សដើម្បីជួយសម្របសម្រួលការងារជំនាញ និងទំនាក់ទំនងជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## II- <u>អំពីការប្រើឈ្មោះជាអក្សរកាត់</u>

1- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះថ្នាក់កណ្តាល ប្រើឈ្មោះជាអក្សរកាត់ "ក" រួមមាន:

- គណៈកម្មការ ក.២៦ គ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ

- គណៈកម្មការ ក.២៧ គ្រប់គ្រងសមាជិកគណបក្សជាកងកម្លាំងនគរបាលជាតិ

- គណៈកម្មការ ក.១៨ គ្រប់គ្រងសមាជិកគណបក្សជាមន្ត្រីនៅក្នុងអង្គការតុលាការ ។

2- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះថ្នាក់រាជធានី ខេត្ត ប្រើឈ្មោះជាអក្សរកាត់ "ខ.២៦ ខ.២៧ និង ខ.១៨" ។

3- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះថ្នាក់ក្រុង ស្រុក ខណ្ឌ ប្រើឈ្មោះជាអក្សរកាត់ "ស.២៦ និង ស.២៧" ។

4- អនុគណៈកម្មការ និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ដែលត្រូវបង្កើតឡើងតាមសំណើរបស់គណៈកម្មការ ក.២៦ និងគណៈកម្មការ ក.២៧ ត្រូវបានប្រើឈ្មោះជាអក្សរកាត់ដូចខាងលើនេះដែរ និងដាក់លេខថែមមួយខ្ទង់នៅខាងក្រោយ ។ ឧទាហរណ៍: អនុគណៈកម្មការ ក.២៦១ គណៈកម្មការ ខ.២៧១ គណៈកម្មការ ស.២៦២ ។

## III- **អំពីក្រុមសមាជិកគណបក្ស**

1- ក្រុមសមាជិកគណបក្ស គឺសំដៅលើសមាជិកគណបក្សទាំងអស់នៃផ្នែក ឬអង្គភាពនីមួយៗ ។ ឧទាហរណ៍: ក្រុមសមាជិកគណបក្សនៃនាយកដ្ឋាន... ក្រុមសមាជិកគណបក្សនៃអង្គភាពលេខ... ។ ត្រូវរៀបចំឲ្យមានប្រធាន និងអនុប្រធានមួយចំនួននៃក្រុមសមាជិកគណបក្សនីមួយៗ ។ ក្រុមសមាជិកគណបក្សនេះអាចចែកជាក្រុមតូចៗចំណុះ(ដូចក្រុមបក្ស) សម្រាប់ការគ្រប់គ្រងសមាជិក និងប្រជុំជីវភាព ។

2- ត្រូវពិនិត្យរៀបចំក្រុមសមាជិកគណបក្សឲ្យចូលរួមជីវភាពបក្ស នៅក្នុងអង្គការចាត់តាំងគណបក្សដែលនៅជិតមូលដ្ឋានឈរជើង ដើម្បីងាយស្រួលក្នុងការដឹកនាំ និងការបំពេញបែបបទសម្រាប់ការគ្រប់គ្រងសមាជិកគណបក្ស ។ តាមរូបភាពនេះ ក្រុមសមាជិកគណបក្សដែលនៅក្នុងយោធភូមិភាគ ឬកងពលតែមួយអាចចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្សនៅខេត្ត ក្រុង ស្រុកខុសគ្នា ។

3- ក្រុមសមាជិកគណបក្សដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការ ក.២៦ គណៈកម្មការ ក.២៧ និងគណៈកម្មការ ក.១៨ ចំណុះថ្នាក់កណ្តាល ត្រូវរៀបចំឲ្យចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្ស ចំណុះគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ដើម្បីងាយស្រួលក្នុងការបំពេញបែបបទគ្រប់គ្រងសមាជិកគណបក្សផង និងចូលរួមសកម្មភាពកសាងពង្រឹងមូលដ្ឋានផង ។

## IV- **អំពីភារកិច្ច**

1- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះថ្នាក់កណ្តាល មានភារកិច្ច:

- រៀបចំការគ្រប់គ្រងក្រុមសមាជិកគណបក្សចំណុះផ្ទាល់ផង និងត្រូវធ្វើការណែនាំអំពីគោលការណ៍វិធានការ ដើម្បីគ្រប់គ្រងសមាជិកគណបក្សដែលជាមន្ត្រីស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួននៅគ្រប់ថ្នាក់ផង ។

- លើកសំណើជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ពិនិត្យ សម្រេច ដើម្បីណែនាំជាគោលការណ៍ដល់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត អំពីការរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស និងការរៀបចំក្រុមសមាជិកគណបក្ស ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួនឲ្យទៅចូលរួមជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្សនៅតាមមូលដ្ឋាននីមួយៗ ។

- សហការជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំក្រុមសមាជិកគណបក្ស ដែលជាមន្ត្រីស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ឲ្យទៅចូលរួមជីវភាពនៅក្នុងអង្គការចាត់តាំងគណបក្សនៅមូលដ្ឋានអោយបានសមស្រប និងគ្រប់គ្រងបាននូវបរិមាណ និងគុណភាពសមាជិកគណបក្ស ។

- ថែបំប៉ន អប់រំ ពង្រឹងសមាជិកគណបក្ស ចូលរួមអនុវត្តកម្មវិធីនយោបាយ សេចក្ដីសម្រេចនានារបស់គណបក្ស និងធ្វើការឃោសនាចលនាមហាជនគាំទ្រគណបក្ស កសាងពង្រីកមុខសញ្ញាល្អដើម្បីឧទ្ទេសនាមជូនគណៈកម្មាធិការគណបក្សពិនិត្យបញ្ចូលជាសមាជិកគណបក្ស ។

2- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ច:

- រៀបចំការគ្រប់គ្រងក្រុមសមាជិកគណបក្សដែលជាមន្ត្រីស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងនៅថ្នាក់របស់ខ្លួនផង និងក្រុមសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិដែលត្រូវបានចូលរួមប្រជុំជីវភាពបក្សនៅក្នុងអង្គការចាត់តាំងគណបក្សចំណុះគណកម្មាធិការគណបក្សនៅថ្នាក់របស់ខ្លួនផង ។

- ក្រុមសមាជិកគណបក្សត្រូវបានចូលរួមប្រជុំជីវភាពបក្សនៅថ្នាក់ណា គណៈកម្មាធិការគណបក្សថ្នាក់នោះទទួលបន្ទុកដឹកនាំ និងបំពេញបែបបទសម្រាប់ការគ្រប់គ្រងសមាជិកគណបក្ស (ដោយមានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់នោះជាជំនួយការ និងមានកិច្ចសហការជាមួយគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះថ្នាក់កណ្ដាល) ។

- ការប្រជុំសមាជិកគណបក្សត្រូវធ្វើនៅទីស្នាក់ការគណបក្ស ឬនៅផ្ទះមន្ត្រី សមាជិកគណបក្ស និងស្ថិតនៅក្រៅម៉ោងការងាររដ្ឋ មិនត្រូវប្រជុំនៅកន្លែងនិងអាគាររបស់រដ្ឋ ហើយសមាជិកដែលមកចូលរួមមិនត្រូវប្រើប្រាស់មធ្យោបាយរបស់រដ្ឋ មិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់ខ្លួនឡើយ ។

## V- <u>**អំពីទម្រង់ប្រើប្រាស់ត្រា និងលិខិតស្នាម**</u>

1- គណៈកម្មាធិការគណបក្សបណ្ដាថ្នាក់អាចប្រើប្រាស់ត្រាគណបក្ស និងក្រដាសដែលមានរូបសញ្ញាគណបក្ស ក្នុងការចេញសេចក្ដីសម្រេច សេចក្ដីណែនាំ និងលិខិតផ្សេងៗបាន ។

2- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សគ្រប់ថ្នាក់មិនត្រូវប្រើប្រាស់ត្រា និងក្រដាសដែលមានរូបសញ្ញាគណបក្សនៅលើលិខិតស្នាមរបស់ខ្លួនទេ ។

3- គណៈកម្មការ ក.២៦ គណៈកម្មការ ក.២៧ និងគណៈកម្មការ ក.១៨ មានត្រាសម្រាប់ប្រើប្រាស់ក្នុងការងារគ្រប់គ្រងសមាជិកគណបក្ស ។ តំរូត្រា នៅរង្វង់ជុំវិញមានអក្សរ "ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ" នៅកណ្ដាលមានអក្សរ "គណៈកម្មការ ក.២៦ ឬគណៈកម្មការ ក.២៧ ឬគណៈកម្មការ ក.១៨" ។

4- អំពីទម្រង់លិខិតរបស់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សបណ្ដាថ្នាក់ នៅកណ្ដាលមានអក្សរពីរបន្ទាត់ "ព្រះរាជាណាចក្រកម្ពុជា - ជាតិ សាសនា ព្រះមហាក្សត្រ" ។ នៅខាងឆ្វេង:

- សម្រាប់ថ្នាក់កណ្ដាល មានអក្សរមួយបន្ទាត់ ឈ្មោះគណៈកម្មការជាអក្សរកាត់តាមការកំណត់ ។

- សម្រាប់អនុគណៈកម្មការចំណុះថ្នាក់កណ្ដាល មានអក្សរពីរបន្ទាត់ ឈ្មោះគណៈកម្មការ និងឈ្មោះអនុគណៈកម្មការជាអក្សរកាត់តាមការកំណត់ ។

- សម្រាប់ថ្នាក់រាជធានី ខេត្ត មានអក្សរពីរបន្ទាត់ ឈ្មោះរាជធានី ខេត្ត និងឈ្មោះសម្គាល់គណៈកម្មការជាអក្សរកាត់តាមការកំណត់ ។

- សម្រាប់ថ្នាក់ ក្រុង ស្រុក ខណ្ឌ មានអក្សរបីបន្ទាត់ ឈ្មោះរាជធានី ខេត្ត ឈ្មោះក្រុង ស្រុក ខណ្ឌ និងឈ្មោះគណៈកម្មការជាអក្សរកាត់តាមការកំណត់ ។

ឧទាហរណ៍:

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការ ក. ២៦**

---

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការ ក.២៦**

**អនុគណៈកម្មការ ក.២៦១**

---

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានីភ្នំពេញ**

**គណៈកម្មការ ខ. ២៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត កណ្ដាល**

**ស្រុក ខ្សាច់កណ្ដាល**

**គណៈកម្មការ ស.២៦**

ចំពោះបញ្ហាជាក់ស្ដែងផ្សេងៗទៀត ត្រូវសិក្សាអនុវត្តតាមស្មារតីនៃសេចក្ដីណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស និងគោរពអនុវត្តតាមច្បាប់ស្ដីអំពីគណបក្សនយោបាយ លក្ខន្តិកៈនៃកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងមន្ត្រីនៃអង្គការតុលាការ ។


គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល
ក.២៦
ក.២៧
ក.១៨
ក.២៦១
ក.២៦២
ក.២៦៣
ក.២៦៤
ក.២៧១
ក.២៧២
ក.២៧៣
ក.២៧៤
គណៈកម្មាធិការបក្សរាជធានី ខេត្ត
ខ.២៦១
ខ.២៦២
ខ.២៦
ខ.២៧
ខ.២៧១
ខ.១៨
គណៈកម្មាធិការបក្សក្រុង ស្រុក ខណ្ឌ
ស.២៦១
ស.២៦២
ស.២៦
ស.២៧
ស.២៧១